# សេចក្តីជូនដំណឹងស្តីពីការប្រកាសជ្រើសរើស
# អ្នកផ្តល់សេវាបច្ចេកទេសសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច

| | |
|---|---|
| ឈ្មោះគម្រោង | រដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ (LGCC II) |
| មុខតំណែងជ្រើសរើស | អ្នកផ្តល់សេវាបច្ចេកទេសសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធឃុំ |
| រយៈពេលផ្តល់សេវា | ចាប់ពី ៨-១២ ខែ |

## ១. សាវតាគម្រោង

គម្រោងរដ្ឋបាលមូលដ្ឋាន និងការប្រែប្រួលអាកាសធាតុ ដំណាក់កាលតភ្ជាប់ ក្នុងគោលបំណងពង្រឹងរដ្ឋបាលមូលដ្ឋានក្នុងការរៀបចំផែនការ និងថវិកាឆ្លើយតបទៅនឹងភាពងាយរងគ្រោះពីការប្រែប្រួលអាកាសធាតុនៅក្នុងតំបន់ និងដើម្បីជាការឆ្ពោះទៅពង្រីកខេត្ត ស្រុកគោលដៅនៅជំហានបន្ត។ គម្រោងរដ្ឋបាលមូលដ្ឋាន តាមរយៈមូលនិធិ PBCR គាំទ្រគម្រោងមូលនិធិឃុំ ប្រមាណ១/៣ នៃមូលនិធិវិនិយោគឃុំនីមួយៗ សម្រាប់គាំទ្រគម្រោងហេដ្ឋារចនាសម្ព័ន្ធ កិច្ចការរដ្ឋបាលស្រុក សម្រាប់គាំទ្រគម្រោង និងសេវាគាំទ្របច្ចេកទេសឯកជន សម្រាប់ការសិក្សាឋានលេខា គ្រោងការគម្រោង កិច្ចលទ្ធកម្ម និងត្រួតពិនិត្យការងារសាងសង់គម្រោងហេដ្ឋារចនាសម្ព័ន្ធឃុំគោលដៅ។ គោលបំណងសំខាន់នៃវិភាជន៍ថវិកាគាំទ្រ គម្រោងមូលនិធិឃុំ គឺគាំទ្រដល់ការអនុវត្តសកម្មភាពជាអាទិភាពរបស់ឃុំ ដែលបានកំណត់នៅក្នុងផែនការអភិវឌ្ឍន៍ឃុំ (CDP/DCP) និងកម្មវិធីវិនិយោគឃុំ (CIP/DIP) និងសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធគាំទ្រដល់ការបន្សាំទៅនឹងការប្រែប្រួលអាកាសធាតុ។ ថវិកាដែលគាំទ្រពីកម្មវិធីនឹងធ្វើការវិភាជន៍ប្រមាណ ៨៥ភាគរយ សម្រាប់ការវិនិយោគទៅលើគម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច អតិប្បរិមា ៣ភាគរយ នៃថវិកាវិនិយោគត្រូវវិភាជន៍ សម្រាប់ចំណាយទៅលើកិច្ចការរដ្ឋបាល និងចំនួនអតិប្បរិមា ១២ភាគរយនៃថវិកាត្រូវវិភាជន៍សម្រាប់ការផ្តល់សេវាបច្ចេកទេសឯកជន។

ក្នុងពេលបច្ចុប្បន្ននេះតម្រូវការផ្តល់សេវាបច្ចេកទេសនេះរួមមាន ការងារការប្រមូលទិន្នន័យព័ត៌មាននៅមូលដ្ឋាន សិក្សាឋានលេខា គ្រោងការគម្រោង ប៉ាន់ស្មានតម្លៃគម្រោង រៀបចំឯកសារដេញថ្លៃ គាំទ្រដំណើរការដេញថ្លៃ និងត្រួតពិនិត្យការអនុវត្តកិច្ចសន្យា។ល។ ការងារបច្ចេកទេសទាំងនេះបានប្រតិបត្តិតាមគោលការណ៍នៃសៀវភៅណែនាំស្តីពីការអនុវត្តគម្រោងមូលនិធិឃុំ សង្កាត់ (PIM)។ ដើម្បីគាំទ្រលកិច្ចការនេះ កម្មវិធីត្រូវការជ្រើសរើសអ្នកផ្តល់សេវាបច្ចេកទេសឯកជនមានគុណសម្បត្តិគ្រប់គ្រាន់ ០១រូប សម្រាប់ជួយក្រុមប្រឹក្សាឃុំ សម្រាប់ជំនួសឱ្យសេវាគាំទ្របច្ចេកទេសលើការងារការសិក្សាគ្រោងការ កិច្ចលទ្ធកម្ម និងត្រួតពិនិត្យការងារសាងសង់គម្រោងហេដ្ឋារចនាសម្ព័ន្ធឃុំ ដែលផ្តល់ដោយមន្ត្រីគាំទ្របច្ចេកទេសនៃទីចាត់ការផែនការ និងវិនិយោគខេត្ត ក្នុងស្រុកបូរីជលសារដូចខាងក្រោម៖

| ល.រ | ស្រុកគោលដៅ | ឃុំ គោលដៅ | ចំនួនអ្នកជំនួយការបច្ចេកទេស |
|---|---|---|---|
| **ខេត្តតាកែវ** | | | |
| ០១ | ស្រុកបូរីជលសារ | ១. ឃុំបូរីជលសារ ២.ឃុំជ័យជោគ ៣. ឃុំដូងខ្ពស់ ៤. ឃុំកំពង់ក្រសាំង ៥. ឃុំគោកពោធិ៍ | ០១ រូប |

## ២. គោលបំណង

គោលបំណងនៃសេវាបច្ចេកទេស គឺជាការផ្តល់ឱ្យក្រុមប្រឹក្សាឃុំ នូវសេវាបច្ចេកទេសប្រកបដោយគុណភាពសម្រាប់គម្រោងហេដ្ឋារចនាសម្ព័ន្ធខ្នាតតូច។ តម្រូវការផ្តល់សេវាបច្ចេកទេសនេះរួមទាំងការប្រមូលទិន្នន័យ ព័ត៌មានបច្ចេកទេសនៅមូលដ្ឋាន សិក្សាលទ្ធភាពគម្រោង គ្រោងការគម្រោង ប៉ាន់ស្មានតម្លៃគម្រោង រៀបចំឯកសារដេញថ្លៃ គាំទ្រដំណើរការដេញថ្លៃ ឯកសារកិច្ចសន្យាសាងសង់ និងត្រួត ពិនិត្យការអនុវត្តកិច្ចសន្យា ។ល។ (មានលម្អិតក្នុងលក្ខខណ្ឌការងាររបស់អ្នកផ្តល់សេវាបច្ចេកទេស)។ គម្រោងនឹងត្រូវសាងសង់ដោយអ្នកទទួលការសាងសង់ ចុះកិច្ចសន្យាជាមួយក្រុមប្រឹក្សាឃុំ ដោយថវិកាមូលនិធិឃុំ និងថវិកាពី PBCR។

## ៣. តម្រូវការលក្ខណៈសម្បត្តិ និងបទពិសោធន៍

អ្នកផ្តល់សេវាបច្ចេកទេសឯកជន(TSC) ត្រូវមានលក្ខណៈសម្បត្តិយ៉ាងតិចមួយក្នុងចំណោមតម្រូវការខាងក្រោម៖

- ✓ យ៉ាងហោចណាស់មានកម្រិតជំនាញ ឬសញ្ញាបត្រវិស្វករជាវាសាស្ត្រកសិកម្ម សំណង់ស៊ីវិល ឬជំនាញប្រហាក់ប្រហែល
- ✓ មានបទពិសោធន៍យ៉ាងតិច៣ឆ្នាំក្នុងការសិក្សាវាស់ស្ទង់ គ្រោងប្លង់គម្រោង ប៉ាន់ស្មានតម្លៃ ត្រួតពិនិត្យគម្រោង ហេដ្ឋារចនាសម្ព័ន្ធជនបទដូចជា ទំនប់ ប្រឡាយ សំណង់ប្រព័ន្ធជាវាសាស្ត្រខ្នាតតូច មធ្យម ឬស្រះ។ល។
- ✓ មានចំណេះដឹងស្តីពីការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងគ្រោះមហន្តរាយ
- ✓ ចេះប្រើកុំព្យូទ័រដូចជាកម្មវិធី Word, Excel, AutoCAD និងប្រព័ន្ធអ៊ិនធឺណេត អ៊ីម៉ែល
- ✓ ត្រូវតែស្ថិតនៅ ឬមានឆន្ទៈធ្វើការនៅក្នុងស្រុកគោលដៅ
- ✓ មានសម្ភារៈ ឧបករណ៍សិក្សាបច្ចេកទេស និងយានជំនិះសម្រាប់ធ្វើដំណើរបានញឹកញាប់ទៅតាមឃុំគោលដៅ។

☞ បុគ្គលដែលមានចំណាប់អារម្មណ៍ត្រូវដាក់ពាក្យស្នើសុំ ប្រវត្តិរូបសង្ខេប និងបទពិសោធន៍ការងារ (CV)។ មុនពេលដាក់ពាក្យសូមពិនិត្យមើលលក្ខខណ្ឌការងារសម្រាប់ផ្តល់សេវាបច្ចេកទេសឯកជន ដែលអាចរកពីក្រុមការងារកម្មវិធីថ្នាក់ខេត្ត ស្រុក ឬទាញយកបានគេហទំព័រ គ.ជ.អ.ប www.ncdd.gov.kh/jobs and procurement

☞ ដាក់ពាក្យស្នើសុំ ប្រវត្តិរូបសង្ខេប និងបទពិសោធន៍ការងារ (CV) និងត្រូវបំពេញក្នុងលិខិត ស្តីពីការសម្តែងចំណាប់អារម្មណ៍(ឧបសម្ព័ន្ធ ក.១) ច្រកក្នុងស្រោមសំបុត្រដាក់នៅតាមស្រុក ខេត្តគោលដៅខាងលើតាមរយៈក្រុមការងារកម្មវិធី។ រាល់ការដាក់ពាក្យស្នើសុំមិនអាចធ្វើតាមអ៊ីម៉ែលបានឡើយ។

☞ កាលបរិច្ឆេទឈប់ទទួលពាក្យនៅម៉ោង ៥ និង៣០នាទីល្ងាច ថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨ ។

☞មានតែអ្នកដែលបានជាប់ក្នុងបញ្ជីសម្រាំងខ្លីនៃបេក្ខជនប៉ុណ្ណោះនឹងត្រូវជូនដំណឹងអំពីការសម្ភាស។

| | |
|---|---|
| សូមទំនាក់ទំនងព័ត៌មានបន្ថែម | **លោកស្រី ប៊ុត ប៊ុណ្ណារី មន្ត្រីសម្របសម្រួលគម្រោងប្រចាំខេត្តតាកែវ**<br>**ទូរស័ព្ទលេខ ៖ ០១៧ ៩៤០ ៦០០** |

ថ្ងៃ សុក្រ ៦កើត ខែពិសាខ ឆ្នាំ ច សំរឹទ្ធស័ក ព.ស ២៥៦១
បុរីជលសារ, ថ្ងៃទី ២០ ខែ មេសា ឆ្នាំ ២០១៨

**អភិបាលស្រុក និងជា**

**ប្រធានគណៈកម្មការជ្រើសរើស**

ឆួយ_សុតំត្រា